**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ
លេខ ៖ ០០៨/២២ ន.ប.ស/ក.អ.ជ

ថ្ងៃសុក្រ ១១ រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

## ស្តីពី វគ្គបណ្តុះបណ្តាលអន្តរជាតិ សិក្សាតាមប្រព័ន្ធវីដេអូ ប្រចាំឆ្នាំ ២០២២ របស់ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិថៃ (TICA)

**យោង៖** - លិខិតលេខ៤៩៧ កបទ.សអ.អប១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចំណារដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ក្រសួងអភិវឌ្ឍន៍ជនបទចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។

នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ សូមជូនដំណឹងដល់មន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ មេត្តាជ្រាបថា ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិថៃ (Thailand International Cooperation Agency : TICA) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ បានផ្តល់វគ្គបណ្តុះបណ្តាលអន្តរជាតិ សិក្សាតាមប្រព័ន្ធវីដេអូ (Online) ចំនួន ៣វគ្គ ដូចខាងក្រោម៖

១. វគ្គ "Sufficiency Economy Philosophy (SEP) in Community-based and Economic Development (CBED)" រៀបចំដោយមហាវិទ្យាល័យសេដ្ឋកិច្ច នៃសាកលវិទ្យាល័យ Kasetsart ចាប់ពីថ្ងៃទី២៣ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ **ផុតកំណត់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២។**

២. វគ្គ "Sustainable Community Development Applying Sufficiency Economy Philosophy from Theory to Practice" រៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ នៃក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី២១-២៥ ខែកុម្ភៈ ឆ្នាំ២០២២ **ផុតកំណត់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។**

៣. វគ្គ "Promoting Sustainable Rural Livelihood and Food Security through System-based Diversified Farming Practices under Sufficiency Economy Philosophy " រៀបចំដោយមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យ Chiang Mai (មិនទាន់កំណត់កាលបរិច្ឆេទ)។

បេក្ខជន-បេក្ខនារី មន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានចំណាប់អារម្មណ៍ចូលរួមវគ្គសិក្សានេះ អាចទាញយកសំណុំបែបបទចុះឈ្មោះតាមរយៈគេហទំព័រ https://tica-thaigov.mfa.go.th/en/content/aitc-2022-calendar ឬស្កេន QR code (ដូចមានជូនភ្ជាប់) សម្រាប់បំពេញរួចដាក់

អាសយដ្ឋាន ÷ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ដីឡូតិ៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
គេហទំព័រ www.mrd.gov.kh E-mail: dtr.mrd@gmail.com

មកនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវចំនួន ០២ច្បាប់ ឲ្យបានមុនថ្ងៃផុតកំណត់របស់វគ្គនីមួយៗ ដើម្បីនាយកដ្ឋានចាត់ការបន្តទាន់ពេលវេលា។

ព័ត៌មានលម្អិត សូមទំនាក់ទំនងជាមួយការិយាល័យបណ្តុះបណ្តាល នៃនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ នៃក្រសួងអភិវឌ្ឍន៍ជនបទ រៀងរាល់ម៉ោងធ្វើការ។៕

https://shortest.link/2emX
1 .Course Outline
2. Online Registration Form

**ប្រធាននាយកដ្ឋាន**

**ឱ្យច_ស៊ីផាត**

<u>ចម្លងជូន</u> ៖
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-រដ្ឋលេខាធិការទទួលបន្ទុក
-អនុរដ្ឋលេខាធិការទទួលបន្ទុក
-អគ្គនាយកទាំងពីរ
*"ដើម្បីគោរពជូនជ្រាប"*
-គ្រប់នាយកដ្ឋាន/មន្ទីរ អ.ជ.ប រាជធានី ខេត្ត
*"ដើម្បីផ្សព្វផ្សាយបន្ត"*
-ឯកសារ កាលប្បវត្តិ